# ព្រះរាជក្រម

នស/រកម/០២០៨/០០៦

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងបរិស្ថាន

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីជីវសុវត្ថិភាព ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០០៧ នាសម័យប្រជុំរដ្ឋសភា លើកទី ៧ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០៨ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភា លើកទី ៤ នីតិកាលទី ២ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ :

# ច្បាប់

# ស្តីពី

# ជីវសុវត្ថិភាព

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.–**

ច្បាប់នេះមានគោលបំណង :

-អនុវត្តគោលការណ៍ប្រុងប្រយ័ត្នស្តីពីជីវសុវត្ថិភាព

-ទប់ស្កាត់ផលប៉ះពាល់អវិជ្ជមានទៅលើការអភិរក្សជីវៈចម្រុះនិងធនធានធម្មជាតិនៃព្រះរាជាណាចក្រកម្ពុជា ដែលបណ្តាលមកពីការផលិត ការដឹកជញ្ជូនឆ្លងដែន ការអភិវឌ្ឍ

-ការលើកដាក់ ការផ្ទេរ ការប្រើប្រាស់ ការស្តុកទុក និង ការបញ្ចេញសារពាង្គកាយកែច្នៃរស់ដែលបង្កើតឡើងដោយជីវបច្ចេកវិទ្យាទំនើប

-ធានាប្រសិទ្ធភាពនៃការអភិរក្សនិងការប្រើប្រាស់ជីវៈចម្រុះដោយនិរន្តរភាពព្រមទាំងយកចិត្តទុកដាក់ចំពោះហានិភ័យដល់សុខភាពមនុស្ស

-ធ្វើឱ្យមានតម្លាភាពក្នុងនីតិវិធីពិនិត្យ និងក្នុងការធ្វើសេចក្តីសម្រេចចំពោះសារពាង្គកាយកែច្នៃរស់ និង សកម្មភាពទាំងឡាយដែលទាក់ទងនឹងសារពាង្គកាយកែច្នៃរស់

-លើកកម្ពស់ការយល់ដឹងអំពីជីវបច្ចេកវិទ្យាទំនើបសំដៅទប់ស្កាត់ហានិភ័យពីការប្រើប្រាស់ និងការបញ្ចេញសារពាង្គកាយកែច្នៃរស់ទៅក្នុងបរិស្ថាន និងសុខភាពមនុស្ស ។

**មាត្រា ២.–**

ក្នុងច្បាប់នេះ ពាក្យបច្ចេកទេសមួយចំនួនមានអត្ថន័យដូចតទៅ :

- **ការប្រើប្រាស់ក្នុងព្រំដែនកំណត់ :** សំដៅដល់ប្រតិបត្តិការ ឬ សកម្មភាពណាមួយដែលទាក់ទងនឹងសារពាង្គកាយកែច្នៃរស់ដែលធ្វើឡើងនៅក្នុងទីកន្លែង ឬ មធ្យោបាយ ឬ ឧបករណ៍ណាមួយ ហើយស្ថិតនៅក្រោមវិធានការដាក់លាក់ដែលទប់ស្កាត់មិនឱ្យសារពាង្គកាយកែច្នៃរស់ទាំងនោះប៉ះពាល់ទៅដល់បរិស្ថានខាងក្រៅ ។

- **ការបញ្ចូលសារពាង្គកាយកែច្នៃរស់នៅក្នុងបរិស្ថានដោយចេតនា :** សំដៅដល់ការប្រើប្រាស់សារពាង្គកាយកែច្នៃរស់ ដែលបានបញ្ញត្តិក្នុងច្បាប់នេះ ដើម្បីយកទៅដាំ ឬ សាបព្រោះ

នៅទីស្រែចំការ ឬ ដាក់ចូលទៅក្នុងទឹក ឬ បញ្ចេញទៅក្នុងបរិយាកាស ការដាក់លក់នៅទីផ្សារ ការធ្វើអំណោយ ការផ្តល់ឱ្យតែពុំមែនជាសារពាង្គកាយកែច្នៃរស់ ប្រើប្រាស់ក្នុងព្រំដែនកំណត់ ឬ ដែលនាំចូលសម្រាប់ប្រើប្រាស់ផ្ទាល់ ជាម្ហូបអាហារ ឬ ចំណីសត្វ ឬ ក៏សម្រាប់ធ្វើការកែច្នៃទៅជាអ្វីផ្សេងទៀតឡើយ ។

**- ជីវបច្ចេកវិទ្យាទំនើប** : សំដៅដល់ការអនុវត្តនូវ :

ក-បច្ចេកទេសអាស៊ីតនុយក្លេអ៊ិកអាំងវីត្រូរួមមានការប្រមូលផ្តុំនូវអាស៊ីតឌីអុកស៊ីរីបូនុយក្លេអ៊ិក និងការចាក់អាស៊ីតនុយក្លេអ៊ិកដោយផ្ទាល់ទៅក្នុងកោសិកា ឬ សរីរាង្គ ។

ខ-ការលាយចូលគ្នានៃកោសិកាដែលមិនមែនជាគ្រួសារតែមួយ ដែលមានលទ្ធភាពយកឈ្នះនូវការផលិតឡើងវិញតាមលក្ខណៈរូបសាស្ត្រធម្មជាតិ ឬ ជាឧបសគ្គដល់ការផ្គុំបញ្ចូលគ្នាឡើងវិញហើយក៏មិនមែនជាបច្ចេកទេសប្រើប្រាស់នៅក្នុងការបង្កាត់ពូជ ឬ ការជ្រើសរើស តាមរបៀបបុរាណ ។

**- ម្ចាស់សំណើ** : សំដៅដល់នីតិបុគ្គល ឬ រូបវន្តបុគ្គលដែលជូនដំណឹងពីបំណងប្រើប្រាស់សារពាង្គកាយកែច្នៃរស់ និង ឬ ស្នើសុំការឯកភាពជាមុនក្នុងការនាំចូល ឬ នាំចេញពីព្រះរាជាណាចក្រកម្ពុជានូវសារពាង្គកាយកែច្នៃរស់ ដើម្បីប្រើប្រាស់ក្នុងគោលបំណងណាមួយ ។

**- សារពាង្គកាយកែច្នៃរស់** : សំដៅដល់សារពាង្គកាយរស់ដែលមានផ្ទុកនូវសេនេទិចថ្មី ទទួលយកតាមរយៈការប្រើប្រាស់ជីវបច្ចេកវិទ្យាទំនើប ។

**- សារពាង្គកាយរស់** : សំដៅដល់អង្គជីវៈចម្រុះទាំងឡាយណាដែលមានសមត្ថភាពក្នុងការផ្ទេរ ឬ ផលិតឡើងវិញនូវសារធាតុសេនេទិច រួមទាំងសារពាង្គកាយដែលមិនអាចបន្តពូជបានវីរុស និងវីរូអ៊ីត ។

**មាត្រា ៣.-**

ច្បាប់នេះអនុវត្តចំពោះការនាំចូល និងនាំចេញ ការប្រើប្រាស់ក្នុងព្រំដែនកំណត់ ការបញ្ចូលសារពាង្គកាយកែច្នៃរស់ទៅក្នុងបរិស្ថានដោយចេតនា និងការប្រើប្រាស់ផ្ទាល់ដើម្បីជាម្ហូបអាហារ ឬ ចំណីសត្វ ឬ ដើម្បីកែច្នៃនូវសារពាង្គកាយកែច្នៃរស់ ដែលអាចប៉ះពាល់ដល់ការអភិរក្ស និងការប្រើប្រាស់ជីវៈចម្រុះដោយនិរន្តរភាព ព្រមទាំងបញ្ហាសុខភាពមនុស្សផងដែរ ។

ច្បាប់នេះនឹងមិនអនុវត្តចំពោះ :

- សារពាង្គកាយកែច្នៃរស់ សម្រាប់ប្រើជាឱសថដែលមានចែងក្នុងកិច្ចព្រមព្រៀងអន្តរជាតិដែលពាក់ព័ន្ធ

- សារពាង្គកាយកែច្នៃរស់ដែលគ្រាន់តែដឹកជញ្ជូនឆ្លងកាត់ តែពុំមានទិសដៅយកមកប្រើនៅក្នុងព្រះរាជាណាចក្រកម្ពុជា

- ប្រភេទសារពាង្គកាយកែច្នៃរស់មួយចំនួនទៀតដែលត្រូវបានលើកលែងដោយស្ថាប័នមានសមត្ថកិច្ច

-ផលិតផលសារពាង្គកាយកែច្នៃរស់មិនមានជីវិត ឬ កីសមាសភាពនៃសារពាង្គកាយ អជីវិត កែច្នៃសេនេទិច ។

**មាត្រា ៤.-**

រូបវន្តបុគ្គល ឬ នីតិបុគ្គល ដែលបានផ្តល់ដំណឹងថាមានបំណងធ្វើសកម្មភាព ឬ ប្រតិបត្តិការទាក់ទងនឹងសារពាង្គកាយកែច្នៃរស់ ដូចជាការប្រើប្រាស់ក្នុងព្រំដែនកំណត់ ការបញ្ចូលទៅក្នុងបរិស្ថានដោយចេតនា និង ឬ ដើម្បីប្រើប្រាស់ដោយផ្ទាល់ធ្វើជាម្ហូបអាហារ ជាចំណីសត្វ ឬ ដើម្បីកែច្នៃនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវមានការឯកភាពជាមុនពីក្រសួងបរិស្ថានមុននឹងសុំការអនុញ្ញាតពីស្ថាប័នមានសមត្ថកិច្ចដែលពាក់ព័ន្ធ ។

សកម្មភាព ឬ ប្រតិបត្តិការណាមួយដែលពាក់ព័ន្ធនឹងសារពាង្គកាយកែច្នៃរស់ ក្រោមបទប្បញ្ញត្តិនៃច្បាប់នេះត្រូវអនុវត្តស្របតាមស្តង់ដារ និងវិធានការស្តីពីការគ្រប់គ្រង និង ត្រួតពិនិត្យអំពីហានិភ័យដូចដែលបានកំណត់ក្នុងនីតិវិធីស្តីពីការវាយតម្លៃហានិភ័យ ដូចបានចែងក្នុងជំពូកទី ៤ ហើយនិងមានចែងលម្អិតដោយប្រកាសរបស់ក្រសួងបរិស្ថាន បន្ទាប់ពីមានការពិគ្រោះយោបល់ជាមួយស្ថាប័នមានសមត្ថកិច្ចដែលពាក់ព័ន្ធ ។

**មាត្រា ៥.-**

រូបវន្តបុគ្គល ឬ នីតិបុគ្គល ដែលទទួលខុសត្រូវចំពោះសកម្មភាព ឬ ប្រតិបត្តិការណាមួយដែលពាក់ព័ន្ធនឹងសារពាង្គកាយកែច្នៃរស់ ក្រោមបទប្បញ្ញត្តិនៃច្បាប់នេះត្រូវធានាថា ការប្រើ

ទំ

ប្រាស់ក្នុងព្រំដែនកំណត់ការបញ្ចូលទៅក្នុងបរិស្ថានដោយចេតនា ការប្រើប្រាស់ផ្ទាល់ ជាម្ហូបអាហារ ជាចំណីសត្វ ឬ សម្រាប់ធ្វើការកែច្នៃ ការនាំចូល និងការនាំចេញសារពាង្គកាយកែច្នៃរស់ ត្រូវបានអនុវត្តតាមបទប្បញ្ញត្តិទាំងឡាយនៃច្បាប់នេះ ដោយអនុវត្តដូចតទៅ :

-រៀបចំយុទ្ធសាស្ត្រគ្រប់គ្រងហានិភ័យ

-មានផែនការសម្រាប់ដោះស្រាយគ្រាមានអាសន្នដោយចៃដន្យ

-បង្កើតយន្តការផ្ទៃក្នុងសម្រាប់ត្រួតពិនិត្យសុវត្ថិភាព

-រាយការណ៍ជាបន្ទាន់ទៅក្រសួងបរិស្ថាន នៅពេលណាដែលអ្នកធ្វើសកម្មភាពនោះបានដឹងថា ព័ត៌មានវិទ្យាសាស្ត្រថ្មីៗបានបង្ហាញឱ្យដឹងថាសកម្មភាព ឬ ប្រតិបត្តិការ និង ឬ សារពាង្គកាយកែច្នៃរស់របស់ខ្លួននឹងបណ្តាលឱ្យមានការប៉ះពាល់ជាអវិជ្ជមានដល់ការអភិរក្ស និងការប្រើប្រាស់ជីវៈចម្រុះដោយនិរន្តរភាព ព្រមទាំងសុខភាពមនុស្សផងដែរ

-ត្រូវមានវិធានការដើម្បីទប់ស្កាត់ជាមុននូវការបញ្ចូលសារពាង្គកាយកែច្នៃរស់ទៅក្នុងបរិស្ថានដោយអចេតនាព្រមទាំងមានវិធានការដោះស្រាយ និងកាត់បន្ថយហានិភ័យទៅលើជីវៈចម្រុះ និងសុខភាពមនុស្ស នៅពេលណាដែលហេតុការណ៍នេះកើតមានឡើង ។

## ជំពូកទី ២
## ស្ថាប័នគ្រប់គ្រង

**មាត្រា ៦.-**

ក្រសួងបរិស្ថាន ដោយសហការជាមួយក្រសួងពាក់ព័ន្ធត្រូវត្រួតពិនិត្យ រាល់សកម្មភាព និងប្រតិបត្តិការដែលពាក់ព័ន្ធនឹងសារពាង្គកាយកែច្នៃរស់ ដែលបានបញ្ញត្តិដោយច្បាប់នេះ ។

ក្រសួងបរិស្ថាន ជាស្ថាប័នបង្គោលជាតិ និងជាស្ថាប័នមានសមត្ថកិច្ចក្នុងការអនុវត្តបទប្បញ្ញត្តិនៃច្បាប់នេះ ។

**មាត្រា ៧.-**

ក្នុងការទទួលខុសត្រូវជាស្ថាប័នបង្គោលជាតិ ដូចបានចែងក្នុងមាត្រា ៦ ខាងលើនេះ ក្រសួងបរិស្ថាន ត្រូវធ្វើជាស្ថាប័នទំនាក់ទំនងដំបូងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងលេខាធិការដ្ឋានអនុសញ្ញាជីវៈចម្រុះ ។

ព្រះបរមរាជវាំង

ក្នុងតួនាទីជាស្ថាប័នមានសមត្ថកិច្ចរបស់ជាតិ ក្រសួងបរិស្ថានត្រូវទទួលខុសត្រូវក្នុងការបំពេញមុខងាររដ្ឋបាល ដែលបានតម្រូវសម្រាប់អនុវត្តច្បាប់នេះ ។ មុខងារទាំងនេះរួមមានការជូនដំណឹងទាន់ពេលវេលាទៅប្រទេសដទៃទៀត និងមណ្ឌលចែកចាយព័ត៌មានជីវសុវត្ថិភាព ព្រមទាំងអង្គការអន្តរជាតិ ដែលពាក់ព័ន្ធទាំងឡាយក្នុងករណីមានហេតុការណ៍ណាមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលបណ្តាលមកពីចលនាឆ្លងដែនណាមួយដោយអចេតនានៃសារពាង្គកាយកែច្នៃរស់ ។

មន្ត្រីរបស់ក្រសួងបរិស្ថានដែលត្រូវបានចាត់តាំង ដោយសហការជាមួយមន្ត្រីជំនាញនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាចធ្វើអធិការកិច្ច អាចប្រមូលយកគំរូតាង ឬ វត្ថុតាង ដើម្បីសម្រួលដល់ការស៊ើបអង្កេតក្នុងទីតាំងដែលបាន ឬ កំពុងមានសកម្មភាព ឬ ប្រតិបត្តិការទាក់ទងនឹងសារពាង្គកាយកែច្នៃរស់ ។

**មាត្រា ៨.-**

រាជរដ្ឋាភិបាល ត្រូវចាត់តាំងបង្កើតក្រុមវិទ្យាសាស្ត្រពិគ្រោះយោបល់មួយតាមសំណើរបស់ក្រសួងបរិស្ថាន ដើម្បីផ្តល់យោបល់វិទ្យាសាស្ត្រ និងបច្ចេកទេសដល់ក្រសួងបរិស្ថានក្នុងការពិនិត្យពាក្យស្នើសុំរបស់ម្ចាស់ស្នើសុំ ការវាយតម្លៃហានិភ័យ និងការធ្វើសេចក្តីសម្រេចយល់ព្រម ព្រមទាំងក្នុងការរៀបចំស្តង់ដារសម្រាប់ទីតាំងសកម្មភាព និងប្រតិបត្តិការទាក់ទងនឹងសារពាង្គកាយកែច្នៃរស់ក្រោមបទប្បញ្ញត្តិនៃច្បាប់នេះ ។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ធ្វើជាប្រធាន និងក្រសួងបរិស្ថានធ្វើជាអនុប្រធាននៃក្រុមវិទ្យាសាស្ត្រ ពិគ្រោះយោបល់ដែលត្រូវបង្កើតឡើង ។

**មាត្រា ៩.-**

រាជរដ្ឋាភិបាល ត្រូវបង្កើតគណៈកម្មាធិការជាតិជីវសុវត្ថិភាពមួយ ដែលដឹកនាំដោយរដ្ឋមន្ត្រីក្រសួងបរិស្ថានដើម្បីដឹកនាំក្នុងការរៀបចំគោលនយោបាយ និងផែនការយុទ្ធសាស្ត្រជីវសុវត្ថិភាព ។

## ជំពូកទី ៣

## ការនាំចូលសារពាង្គកាយកែច្នៃរស់

**មាត្រា ១០.-**

ការនាំចូលជាលើកទីមួយនូវសារពាង្គកាយកែច្នៃរស់ មកក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីប្រើប្រាស់ក្នុងព្រំដែនកំណត់ត្រូវបានតម្រូវឱ្យមានការវាយតម្លៃហានិភ័យ ព្រមទាំងមានការយល់ព្រមពីក្រសួងបរិស្ថានជាមុន មុននឹងស្នើសុំការអនុញ្ញាតនាំចូលពីស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ។

**មាត្រា ១១.-**

ការនាំចូលសារពាង្គកាយកែច្នៃរស់មកក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីបញ្ចូលទៅក្នុងបរិស្ថានដោយចេតនា ត្រូវបានតម្រូវឱ្យមានការវាយតម្លៃហានិភ័យ ព្រមទាំងមានការយល់ព្រមពីក្រសួងបរិស្ថានជាមុន មុននឹងស្នើសុំការអនុញ្ញាតនាំចូលពីស្ថាប័នមានសមត្ថកិច្ចដែលពាក់ព័ន្ធ ។

ម្ចាស់ស្នើត្រូវដាក់ពាក្យទៅក្រសួងបរិស្ថានអំពីគោលបំណងនៃការនាំចូលរបស់ខ្លួន ។

**មាត្រា ១២.-**

ក្រសួងបរិស្ថានត្រូវឆ្លើយតបជាលាយលក្ខណ៍អក្សរស្តីពីការបានទទួលពាក្យស្នើសុំទៅម្ចាស់ស្នើសុំវិញក្នុងរយៈពេលយ៉ាងយូរកៅសិប (៩០)ថ្ងៃ ចាប់ពីថ្ងៃទទួលពាក្យស្នើសុំនេះ ដោយបញ្ជាក់ពីយោបល់របស់ខ្លួនថា ម្ចាស់ស្នើសុំអាចអនុវត្តកិច្ចដំណើរការសុំការយល់ព្រមជាមុនបាន ឬ ពុំបាន ។

**មាត្រា ១៣.-**

ក្នុងរយៈពេលយ៉ាងយូរពីររយចិតសិប (២៧០) ថ្ងៃ បន្ទាប់ពីបានទទួលពាក្យស្នើសុំ ដូចបានចែងក្នុងមាត្រា ១១ និងមាត្រា ១២ នៃច្បាប់នេះ ក្រសួងបរិស្ថានត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅម្ចាស់ស្នើសុំ និងទៅបណ្តាញផ្សព្វផ្សាយព័ត៌មានជីវសុវត្ថិភាពជាតិស្តីអំពីការសម្រេចរបស់ខ្លួន ។

**មាត្រា ១៤.–**

ការនាំចូលជាលើកទីមួយនូវសារពាង្គកាយកែច្នៃរស់ មកក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីប្រើប្រាស់ផ្ទាល់ ជាម្ហូបអាហារ ជាចំណីសត្វ ឬ សម្រាប់ធ្វើការកែច្នៃ ត្រូវបានតម្រូវឱ្យមានការវាយតម្លៃហានិភ័យ ព្រមទាំងមានការយល់ព្រមពីក្រសួងបរិស្ថានជាមុន មុននឹងស្នើសុំការអនុញ្ញាតនាំចូលពីស្ថាប័នមានសមត្ថកិច្ចដែលពាក់ព័ន្ធ ។

រូបវន្តបុគ្គល ឬ នីតិបុគ្គល ដែលមានបំណងនាំចូលសារពាង្គកាយកែច្នៃរស់មកក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីប្រើប្រាស់ផ្ទាល់ ជាម្ហូបអាហារ ជាចំណីសត្វ ឬ សម្រាប់ធ្វើការកែច្នៃត្រូវផ្តល់ជូនទៅក្រសួងបរិស្ថានពិនិត្យនូវវិញ្ញាបនប័ត្រជាលាយលក្ខណ៍អក្សរពីស្ថាប័នមានសមត្ថកិច្ចនៃប្រទេសដែលនាំចេញ ដោយបញ្ជាក់ពីភាពត្រឹមត្រូវនៃព័ត៌មានទាក់ទងនឹងសារពាង្គកាយកែច្នៃរស់ដែលត្រូវនាំចូល ។

**មាត្រា ១៥.–**

នៅពេលដែលក្រសួងបរិស្ថាន បានសម្រេចយល់ព្រមចំពោះសារពាង្គកាយកែច្នៃរស់ ដើម្បីប្រើប្រាស់ផ្ទាល់ ជាម្ហូបអាហារ ជាចំណីសត្វ ឬ សម្រាប់ធ្វើការកែច្នៃនោះ ក្រសួងបរិស្ថានត្រូវជូនដំណឹងដល់សមាជិកទាំងឡាយនៃពិធីសារកាតាហេហ្សណា តាមរយៈមណ្ឌលចែកផ្សាយព័ត៌មានជីវសុវត្ថិភាពក្នុងរយៈពេលដប់ប្រាំ (១៥) ថ្ងៃ ។

**មាត្រា ១៦.–**

លិខិតយល់ព្រមជាគោលការណ៍ របស់ក្រសួងបរិស្ថានត្រូវភ្ជាប់ជាមួយនឹងការអនុញ្ញាតនាំចូលសារពាង្គកាយកែច្នៃរស់ ។

## ជំពូកទី ៤
## ការនាំចេញសារពាង្គកាយកែច្នៃរស់

**មាត្រា ១៧.–**

រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលមានបំណងនាំចេញពីព្រះរាជាណាចក្រកម្ពុជានូវសារពាង្គកាយកែច្នៃរស់ដែលបានបញ្ញត្តិដោយច្បាប់នេះ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ

ជាមុនទៅស្ថាប័នជាតិមានសមត្ថកិច្ចនៃប្រទេសដែលនាំចូល មុននឹងដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតនាំចេញពីក្រសួងមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ១៨.-**

ក្រសួងមានសមត្ថកិច្ចដែលពាក់ព័ន្ធ អាចចេញលិខិតអនុញ្ញាតនាំចេញសារពាង្គកាយកែច្នៃរស់ពីព្រះរាជាណាចក្រកម្ពុជា បន្ទាប់ពីបានទទួលការឯកភាពជាលាយលក្ខណ៍អក្សរពីស្ថាប័នមានសមត្ថកិច្ចនៃប្រទេសនាំចូល ។ លិខិតឯកភាពពីភាគីនាំចូល ត្រូវភ្ជាប់ជាមួយនឹងលិខិតអនុញ្ញាតនាំចេញ និង ឬ ឯកសារដទៃទៀតទាក់ទងនឹងការវេចខ្ចប់ ការលើកដាក់នាំចេញ ។

**មាត្រា ១៩.-**

អ្នកនាំចេញសារពាង្គកាយកែច្នៃរស់ពីព្រះរាជាណាចក្រកម្ពុជា ត្រូវមានការបញ្ជាក់ជាលាយលក្ខណ៍អក្សរពីក្រសួងបរិស្ថានពីភាពត្រឹមត្រូវនៃរាល់ព័ត៌មានដែលខ្លួនបានផ្តល់ទាក់ទងនឹងសារពាង្គកាយកែច្នៃរស់ត្រូវនាំចេញ ។ លិខិតបញ្ជាក់នេះត្រូវភ្ជាប់ជាមួយនឹងលិខិតអនុញ្ញាតនាំចេញ និង ឬ ឯកសារដទៃទៀតទាក់ទងនឹងការវេចខ្ចប់ ការលើក ដាក់នាំចេញ ។

## ជំពូកទី ៥
## ការវាយតម្លៃហានិភ័យ

**មាត្រា ២០.-**

ក្រសួងបរិស្ថាន ត្រូវធានាឱ្យមានការវាយតម្លៃដ៏សមស្របអំពីហានិយភ័យ ចំពោះរាល់សកម្មភាពទាក់ទងនឹងសារពាង្គកាយកែច្នៃរស់ដែលបានបញ្ញត្តិក្នុងច្បាប់នេះ ។

**មាត្រា ២១.-**

ម្ចាស់សំណើត្រូវទទួលបន្ទុកក្នុងការវាយតម្លៃហានិភ័យ និងទទួលរ៉ាប់រងលើចំណាយទាំងអស់សម្រាប់ការវាយតម្លៃនេះ ។ នៅពេលបានទទួលលទ្ធផលនៃការវាយតម្លៃហានិភ័យ និងឯកសារពាក់ព័ន្ធទាំងឡាយដែលបានតម្រូវដោយច្បាប់នេះ ក្រសួងបរិស្ថាននឹងផ្តល់ការ

ROYAUME DU CAMBODGE * LE MINISTERE DU PALAIS ROYAL *

ឯកភាពជាគោលការណ៍ដោយមាន ឬ គ្មានល័ក្ខខ័ណ្ឌ ឬ តម្រូវឱ្យផ្តល់ព័ត៌មានបន្ថែម ឬ បដិសេធមិនផ្តល់ការឯកភាព ។

## ជំពូកទី ៦
## ឯកសារសារពាង្គកាយកែច្នៃរស់

**មាត្រា ២២.-**

រូបវន្តបុគ្គល ឬ នីតិបុគ្គល ដែលនាំចូល ឬ នាំចេញពីព្រះរាជាណាចក្រកម្ពុជានូវសារពាង្គកាយកែច្នៃរស់ក្នុងគោលបំណងណាមួយក៏ដោយ ត្រូវផ្តល់នូវឯកសារភ្ជាប់ជាមួយដោយបញ្ជាក់យ៉ាងច្បាស់លាស់ពីអត្តសញ្ញាណនៃសារពាង្គកាយកែច្នៃរស់នោះ ពិតជាសារពាង្គកាយកែច្នៃរស់ប្រាកដមែន ព្រមទាំងបញ្ជាក់អំពីល័ក្ខខ័ណ្ឌតម្រូវការសម្រាប់សុវត្ថិភាពក្នុងការវេចខ្ចប់ ការលើកដាក់ ការដឹកជញ្ជូន ការប្រើប្រាស់ និងការរក្សាទុក ។

**មាត្រា ២៣.-**

លើកលែងតែមានបទប្បញ្ញត្តិច្បាប់ចែងដោយឡែកពីសារពាង្គកាយកែច្នៃរស់ដែលត្រូវនាំចូល ឬ នាំចេញពីព្រះរាជាណាចក្រកម្ពុជា ត្រូវភ្ជាប់ជាមួយនូវឯកសារបញ្ជាក់ល័ក្ខខ័ណ្ឌដូចខាងក្រោមនេះ ៖

-ចំពោះសារពាង្គកាយកែច្នៃរស់ ដើម្បីប្រើប្រាស់ផ្ទាល់ ជាម្ហូបអាហារ ជាចំណីសត្វ ឬ សម្រាប់ធ្វើការកែច្នៃត្រូវបញ្ជាក់ឱ្យច្បាស់ថា ទំនិញទាំងនោះអាចផ្ទុកនូវសារពាង្គកាយកែច្នៃរស់ ហើយនឹងមិនមានបំណងបញ្ចូលទៅក្នុងបរិស្ថាន ដោយចេតនាឡើយ

-ចំពោះសារពាង្គកាយកែច្នៃរស់ ដើម្បីបញ្ចូលទៅក្នុងបរិស្ថានដោយចេតនា ត្រូវបញ្ជាក់ឱ្យច្បាស់ពីអត្តសញ្ញាណលក្ខណៈពាក់ព័ន្ធ ល័ក្ខខ័ណ្ឌតម្រូវការពីសុវត្ថិភាពក្នុងការវេចខ្ចប់ ការលើកដាក់ ការដឹកជញ្ជូន ការប្រើប្រាស់ និងការរក្សាទុកនិងត្រូវបញ្ជាក់ផងដែរពីមន្ត្រីទំនាក់ទំនងដើម្បីទទួលព័ត៌មានបន្ថែមព្រមទាំងបញ្ជាក់ថា ការដឹកជញ្ជូនឆ្លងដែននូវសារពាង្គកាយកែច្នៃរស់នេះ ស្របតាមបញ្ញត្តិនៃពិធីសារកាតាហេសុណាសម្រាប់អ្នកនាំចេញ

ROYAUME DU CAMBODGE
ក្រសួងព្រះបរមរាជវាំង
MINISTERE DU PALAIS ROYAL

ស

-ចំពោះសារធាតុកាយកែខ្មៃរស់ ដើម្បីប្រើប្រាស់ក្នុងព្រំដែនកំណត់ ត្រូវកំណត់ឱ្យច្បាស់ថាជាសារធាតុកាយកែខ្មៃរស់និងបញ្ជាក់ឱ្យដឹងពីល័ក្ខខ័ណ្ឌ តម្រូវការសុវត្ថិភាពក្នុងការវេចខ្ចប់ ការលើកដាក់ ការដឹកជញ្ជូន ការប្រើប្រាស់ និងការរក្សាទុក និងត្រូវបញ្ជាក់ផងដែរពីមន្ត្រីទំនាក់ទំនងដើម្បីទទួលព័ត៌មានបន្ថែមទៀត ក្នុងនោះត្រូវរៀបរាប់ពីឈ្មោះ អាសយដ្ឋានរបស់បុគ្គល និងស្ថាប័នដែលត្រូវប្រគល់សារធាតុកាយកែខ្មៃរស់ ។

**មាត្រា ២៤.–**

សារធាតុកាយកែខ្មៃរស់ និងផលិតផលដែលមានផ្ទុកសារធាតុកាយកែខ្មៃរស់ត្រូវមានបិទផ្លាកសញ្ញាច្បាស់លាស់ ។

## ជំពូកទី ៧
## ព័ត៌មានសម្ងាត់

**មាត្រា ២៥.–**

ក្រសួងបរិស្ថាន តម្រូវឱ្យម្ចាស់ស្នើសុំផ្តល់ព័ត៌មានមួយចំនួនដែលម្ចាស់ស្នើចាត់ទុកថាជាព័ត៌មានសម្ងាត់ ដើម្បីធានារក្សាការសម្ងាត់ ។

ក្នុងករណីដូចបានចែងខាងលើនេះ ក្រសួងបរិស្ថានមានសិទ្ធិធ្វើការសម្រេចថាយល់ព្រម ឬ មិនយល់ព្រមចាត់ទុកថាជាព័ត៌មានសម្ងាត់ ដែលម្ចាស់ស្នើបានស្នើ ។

**មាត្រា ២៦.–**

ក្រសួងបរិស្ថានត្រូវចេញសេចក្តីសម្រេចថាយល់ព្រម ឬ បដិសេធជាលាយលក្ខណ៍អក្សរលើការស្នើព័ត៌មានសម្ងាត់នោះ ដោយផ្តល់នូវមូលហេតុសមស្របដល់ម្ចាស់ស្នើ ។

**មាត្រា ២៧.–**

ក្រសួងបរិស្ថាន និងស្ថាប័នពាក់ព័ន្ធត្រូវរក្សាការពារព័ត៌មានសម្ងាត់ដូចបានចែងក្នុងមាត្រា ២៥ នៃច្បាប់នេះ ។ ការប្រើប្រាស់ ឬ អនុញ្ញាតឱ្យប្រើប្រាស់ព័ត៌មានសម្ងាត់ទាំងនោះត្រូវមានការឯកភាពជាលាយលក្ខណ៍អក្សរពីម្ចាស់ស្នើ មុនធ្វើការផ្សព្វផ្សាយជាសាធារណៈ ។

**មាត្រា ២៨.—**

បែបបទលម្អិតពីការរក្សាព័ត៌មានសម្ងាត់ និងការផ្សព្វផ្សាយជាសាធារណៈនឹងត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី ៨
## ការសើរើពិនិត្យសេចក្តីសម្រេចឡើងវិញ

**មាត្រា ២៩.—**

ក្រសួងបរិស្ថាន និងស្ថាប័នពាក់ព័ន្ធអាចធ្វើការសើរើពិនិត្យឡើងវិញអំពីការសម្រេចណាមួយរបស់ខ្លួន ចំពោះសកម្មភាពប្រតិបត្តិការ ការនាំចូល ឬ នាំចេញសារពាង្គកាយកែច្នៃរស់ នៅពេលណាមួយដែលបានទទួលព័ត៌មានថ្មីច្បាស់លាស់ បញ្ជាក់ថា សារពាង្គកាយកែច្នៃរស់ ឬ សកម្មភាពប្រតិបត្តិការ ការនាំចូល ឬ នាំចេញពាក់ព័ន្ធអាចបណ្តាលឱ្យមានការប៉ះពាល់ជាអវិជ្ជមានដល់ការអភិរក្ស និងការប្រើប្រាស់ជីវៈចម្រុះដោយនិរន្តរភាពព្រមទាំងគិតដល់បញ្ហាហានិភ័យចំពោះសុខភាពមនុស្ស ។

នៅពេលណាដែលក្រសួងបរិស្ថានធ្វើការសើរើពិនិត្យឡើងវិញ ចំពោះបញ្ហាសារពាង្គកាយកែច្នៃរស់ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់នេះ ក្រសួងបរិស្ថានត្រូវជូនដំណឹងដល់មណ្ឌលចែកផ្សាយព័ត៌មានជីវសុវត្ថិភាព ។

**មាត្រា ៣០.—**

ក្នុងករណីក្រសួងបរិស្ថាន ធ្វើការផ្លាស់ប្តូរសេចក្តីសម្រេចយល់ព្រម ចំពោះការនាំចូលដើម្បីគោលបំណងណាមួយនូវសារពាង្គកាយកែច្នៃរស់ នោះក្រសួងបរិស្ថានត្រូវជូនដំណឹងពីមូលហេតុនៃការផ្លាស់ប្តូរនេះដល់ម្ចាស់ស្នើដែលបានដាក់ពាក្យសុំពីមុនមកនិងឬបានទទួលការឯកភាពចំពោះការនាំចូលក្នុងរយៈពេលសាមសិប (៣០)ថ្ងៃ ។

**មាត្រា ៣១.—**

ម្ចាស់ស្នើដែលបានស្នើសុំការឯកភាពជាមុន ក្នុងការនាំចូលសារពាង្គកាយកែច្នៃរស់របស់ខ្លួនក្នុងគោលបំណងណាមួយដែលត្រូវបានទទួលការបដិសេធ អាចធ្វើការស្នើសុំទៅក្រសួង

បរិស្ថានពិនិត្យឡើងវិញពីការសម្រេចរបស់ខ្លួន ក្នុងករណីដែលម្ចាស់ស្នើអាចរកបានព័ត៌មានវិទ្យាសាស្ត្របច្ចេកទេសបន្ថែមទៀត ឬ ក្នុងករណីដែលខ្លួនយល់ថាអាចនាំទៅរកការធ្វើការកែប្រែលទ្ធផលនៃការវាយតម្លៃហានិភ័យ ។

បន្ទាប់ពីបានពិចារណាលើព័ត៌មានថ្មីៗ និងឬការប្រែប្រួលនៃកាលៈទេសៈទាំងនេះរួចហើយ ក្រសួងបរិស្ថានអាចធ្វើការពិនិត្យឡើងវិញបាន ឬ ក៏រក្សាទុកសេចក្តីសម្រេចរបស់ខ្លួនពីមុនមក ហើយត្រូវជូនដំណឹងទៅម្ចាស់ស្នើវិញក្នុងរយៈពេលកៅសិប(៩០) ថ្ងៃដោយមានបញ្ជាក់ពីមូលហេតុនៃការសម្រេចរបស់ខ្លួន ។

## ជំពូកទី ៩
## ការផ្តល់ព័ត៌មាន ការលើកកម្ពស់ការយល់ដឹង និងការចូលរួមរបស់សាធារណជន

**មាត្រា ៣២.-**

ក្រសួងបរិស្ថាន និងស្ថាប័នពាក់ព័ន្ធត្រូវលើកកម្ពស់ការយល់ដឹង ធ្វើការអប់រំ និងផ្តល់ព័ត៌មានគ្រប់គ្រាន់ដល់សាធារណជនលើបញ្ហាជីវសុវត្ថិភាព ដែលបានបញ្ញត្តិដោយច្បាប់នេះ ។

**មាត្រា ៣៣.-**

ក្រសួងបរិស្ថាន និងស្ថាប័នពាក់ព័ន្ធ ត្រូវផ្លាស់ប្តូរព័ត៌មានទាក់ទងនឹងបញ្ហាសារពាង្គកាយកែច្នៃរស់ជាប្រចាំ ។

**មាត្រា ៣៤.-**

ក្រសួងបរិស្ថាន និងស្ថាប័នពាក់ព័ន្ធ ត្រូវលើកទឹកចិត្តដល់ការចូលរួមផ្តល់យោបល់របស់សាធារណជនក្នុងការធ្វើសេចក្តីសម្រេច និងធ្វើផែនការគ្រប់គ្រងទាក់ទងនឹងបញ្ហាជីវសុវត្ថិភាព ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *
ព្រះបរមរាជវាំង

## ជំពូកទី ១០

## ទោសប្បញ្ញត្តិ

**មាត្រា ៣៥.–**

ទណ្ឌកម្មនៃបទល្មើសជីវសុវត្ថិភាពរួមមាន : ទោសជាប់ពន្ធនាគារ ទោសពិន័យជាប្រាក់ ការពិន័យអន្តរការណ៍ ការរឹបអូស និងការព្រមាន ។

ទោសជាប់ពន្ធនាគារ ទោសពិន័យជាប្រាក់ និងការរឹបអូសជាសមត្ថកិច្ចរបស់តុលាការ ។

ការពិន័យអន្តរការណ៍ និងការព្រមាន ជាសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន ។

ក្នុងករណីជនល្មើសមិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍ ក្រសួងបរិស្ថានត្រូវរៀបចំសំណុំរឿងប្តឹងទៅតុលាការមានសមត្ថកិច្ចក្នុងរយៈពេលដប់ប្រាំ (១៥) ថ្ងៃ គិតចាប់ពីថ្ងៃចុងក្រោយដែលក្រសួងបរិស្ថានតម្រូវឱ្យជនល្មើសបង់ប្រាក់ពិន័យ ។

**មាត្រា ៣៦.–**

ប្រាក់ពិន័យតាមអំណាចសាលក្រម ឬ សាលដីកាតុលាការ ប្រាក់ពិន័យអន្តរការណ៍ ប្រាក់បានមកពីការលក់វត្ថុតាង ត្រូវបង់ចូលថវិកាជាតិ ។

**មាត្រា ៣៧.–**

រូបវន្តបុគ្គល ឬ នីតិបុគ្គល ដែលបានទទួលការអនុញ្ញាត និងកំពុងដំណើរការសកម្មភាពទាក់ទងនឹងសារពាង្គកាយកែច្នៃរស់បានដឹងថាព័ត៌មានវិទ្យាសាស្ត្រសំខាន់ថ្មីៗ រកឃើញពីហានិភ័យបណ្តាលមកពីសកម្មភាពរបស់ខ្លួនអាចបង្កហេតុប៉ះពាល់ជាអវិជ្ជមានទៅលើការអភិរក្សនិងការប្រើប្រាស់ជីវៈចម្រុះដោយនិរន្តរភាព និងសុខភាពមនុស្ស ប៉ុន្តែខ្លួនពុំបានរាយការណ៍ទៅក្រសួងបរិស្ថានត្រូវទទួលការព្រមានជាលាយលក្ខណ៍អក្សរ ។

ក្រសួងបរិស្ថានត្រូវធ្វើការពិនិត្យសេចក្តីសម្រេចរបស់ខ្លួនឡើងវិញ និង ឬ បដិសេធលិខិតអនុញ្ញាត ។

**មាត្រា ៣៨.–**

រូបវន្តបុគ្គលឬ នីតិបុគ្គល ឬ អ្នកធ្វើសកម្មភាពណាមួយដែលរារាំង ឬ ធ្វើឱ្យមានការរារាំងមន្ត្រីរបស់ក្រសួងបរិស្ថាន មិនឱ្យបំពេញភារកិច្ចរបស់ខ្លួនតាមបទប្បញ្ញត្តិនៃមាត្រា ៧ វាក្យខណ្ឌ

ទី ៣ នៃច្បាប់នេះត្រូវពិន័យអន្តរការណ៍ជាប្រាក់ពីប្រាំសែន (៥០០.០០០)រៀល ដល់មួយលាន (១.០០០.០០០)រៀល ។

ក្នុងករណីពុំរាងចាល ក្រសួងបរិស្ថានត្រូវរៀបចំសំណុំរឿងប្តឹងទៅតុលាការមានសមត្ថកិច្ច ។

**មាត្រា ៣៩.-**

ជនណាដែលល្មើសនឹងមាត្រា ១០ មាត្រា ១១ ឬ មាត្រា ១៤ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ចាប់ពីមួយលាន (១.០០០.០០០)រៀល ដល់ប្រាំលាន (៥.០០០.០០០)រៀល ។

ក្នុងករណីមិនរាងចាលត្រូវពិន័យទ្វេមួយជាពីរ ដោយពុំទាន់គិតបញ្ចូលពីទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះបច្ច័យនៃបទល្មើសដែលបណ្តាលឱ្យប៉ះពាល់ដល់ការអភិរក្ស និងការប្រើប្រាស់ជីវៈចម្រុះដោយនិរន្តរភាព និង ប៉ះពាល់ដល់សុខភាពមនុស្ស ។

**មាត្រា ៤០.-**

ជនណាដែលមានចេតនាផ្តល់ព័ត៌មានដែលតម្រូវដោយមាត្រា ២២ ខុសពីការពិត ឬដោយពង្វាងពីការពិត ឬ ដោយធ្វើឱ្យភ័ន្តច្រឡំ ទោះតាមវិធីណាក៏ដោយនឹងត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពីមួយ(០១)ឆ្នាំ ដល់ប្រាំ (០៥)ឆ្នាំ និង ឬ ត្រូវពិន័យជាប្រាក់ពីបួនលាន(៤.០០០.០០០)រៀលដល់ម្ភៃលាន (២០.០០០.០០០)រៀល ។

ក្នុងករណីមិនរាងចាលត្រូវផ្តន្ទាទោសទ្វេដង ទាំងទោសពិន័យជាប្រាក់ ទាំងទោសដាក់ពន្ធនាគារដោយពុំទាន់គិតបញ្ចូលនូវទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះបច្ច័យនៃបទល្មើសដែលបង្កឱ្យមានការប៉ះពាល់ធ្ងន់ធ្ងរដល់ការអភិរក្ស និង ការប្រើប្រាស់ជីវៈចម្រុះដោយនិរន្តរភាព និង ឬ សុខភាពមនុស្ស ។

**មាត្រា ៤១.-**

ក្នុងករណីមានភស្តុតាងច្បាស់លាស់បង្ហាញឱ្យឃើញថា រូបវន្តបុគ្គល ឬ នីតិបុគ្គល ដូចបានចែងក្នុងមាត្រា ៣៧ មានចេតនាលាក់កំបាំងព័ត៌មានពីហានិភ័យនៃសកម្មភាពសារពាង្គកាយកែច្នៃរស់របស់ខ្លួនទៅលើជីវៈចម្រុះ និងសុខភាពមនុស្ស ត្រូវផ្តន្ទាទោសពិន័យជាប្រាក់

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

17/22

ពីដប់លាន (១០.០០០.០០០)រៀល ដល់ហាសិបលាន (៥០.០០០.០០០)រៀល ឬ ផ្តន្ទាទោសដាក់ពន្ធនាគារពីមួយ (០១)ឆ្នាំ ដល់ប្រាំ (០៥)ឆ្នាំ ឬ ទោសទាំងពីរនេះ ។

**មាត្រា ៤២.-**

វត្ថុតាងនៃសកម្មភាពខុសច្បាប់ទាំងអស់ ដែលទាក់ទងនឹងសារពាង្គកាយកែច្នៃរស់ ដូចបានកំណត់ក្នុងមាត្រា ៣៩ និងមាត្រា ៤០ រួមទាំងឧបករណ៍ដែលជាកម្មវត្ថុបង្កឱ្យមានបទល្មើសត្រូវរឹបអូសជាសម្បត្តិរដ្ឋ ។ ការរឹបអូស និងការសម្រេចលើវត្ថុតាងជាសមត្ថកិច្ចតុលាការ ។

**មាត្រា ៤៣.-**

ភ្នាក់ងារអធិការកិច្ច ឬ មន្ត្រីបរិស្ថានរូបណាដែលមានការធ្វេសប្រហែស ខ្វះការប្រុងប្រយ័ត្ន ឬ មិនគោរពបទប្បញ្ញត្តិនៃច្បាប់នេះត្រូវទទួលទណ្ឌកម្មខាងវិន័យរដ្ឋបាល និង/ឬ ត្រូវចោទប្រកាន់ចំពោះមុខតុលាការ ។

ភ្នាក់ងារអធិការកិច្ច ឬ មន្ត្រីបរិស្ថានរូបណាដែលសមគំនិតនឹងអ្នកប្រព្រឹត្តបទល្មើស ឬ ជួយសម្រួលដល់ការប្រព្រឹត្តបទល្មើស ត្រូវផ្តន្ទាទោសដូចគ្នាដែរ ។

## ជំពូកទី ១១

## អវសានប្បញ្ញត្តិ

**មាត្រា ៤៤.-**

នីតិវិធីអនុវត្តបទប្បញ្ញត្តិដែលមានចែងក្នុង :

-មាត្រា ៦ មាត្រា ១៥ មាត្រា ១៧ មាត្រា ២០ មាត្រា ២២ មាត្រា ២៥ និង មាត្រា ៣១ នៃច្បាប់នេះត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងបរិស្ថាន ។

**មាត្រា ៤៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ ២០០៨

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

នស/រកម.០៩០២.១៣៣ **នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន

**ហត្ថលេខា**

**ម៉ុក ម៉ារ៉េត**

លេខ : ១៣៩ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៨

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊ុន ជិនកេន**

## ឧបសម្ព័ន្ធ

## វាក្យសព្ទ

**ការប្រើប្រាស់ក្នុងព្រំដែនកំណត់**( Contained uses ) ៖ សំដៅដល់ប្រតិបត្តិការ ឬសកម្មភាពណាមួយ ដែលទាក់ទងនឹងសារពាង្គកាយកែច្នៃរស់ដែលធ្វើឡើងនៅក្នុងទីកន្លែង ឬ មធ្យោបាយ ឬ ឧបករណ៍ណាមួយហើយស្ថិតនៅក្រោមវិធានការជាក់លាក់ ដែលទប់ស្កាត់មិនឱ្យសារពាង្គកាយកែច្នៃរស់ទាំងនោះប៉ះពាល់ទៅដល់បរិស្ថានខាងក្រៅ ។

**ការបញ្ចូលសារពាង្គកាយកែច្នៃរស់នៅក្នុងបរិស្ថានដោយចេតនា** ៖ សំដៅដល់ការប្រើប្រាស់សារពាង្គកាយកែច្នៃរស់ ដែលបានបញ្ញត្តិក្នុងច្បាប់នេះ ដើម្បីយកទៅដាំ ឬ សាបព្រោះនៅទីស្រែចំការ ឬ ដាក់ចូលទៅក្នុងទឹក ឬ បញ្ចេញទៅក្នុងបរិយាកាស ការដាក់លក់នៅទីផ្សារ ការធ្វើអំណោយ ការផ្តល់ឱ្យ តែពុំមែនជាសារពាង្គកាយកែច្នៃរស់ ប្រើប្រាស់ក្នុងព្រំដែនកំណត់ ឬ ដែលនាំចូលសម្រាប់ប្រើប្រាស់ផ្ទាល់ជាម្ហូបអាហារ ឬ ចំណីសត្វ ឬ ក៏សម្រាប់ធ្វើការកែច្នៃទៅជាអ្វីផ្សេងទៀតឡើយ ។

**ជីវបច្ចេកវិទ្យាទំនើប** (Modern Biotechnology) ៖ សំដៅដល់ការអនុវត្តនូវ

ក-បច្ចេកទេសអាស៊ីតនុយក្លេអ៊ិកអាំងវីត្រូ (In-vitro Nuclei Acid Techniques) រួមមានការប្រមូលផ្តុំនូវអាស៊ីតឌីអុកស៊ីរីបូនុយក្លេអ៊ិកនិងការចាក់អាស៊ីតនុយក្លេអ៊ិកដោយផ្ទាល់ទៅក្នុងកោសិកា ឬ សរីរាង្គ ។

ខ-ការលាយចូលគ្នានៃកោសិកាដែលមិនមែនត្រូវសារតែមួយ ដែលមានលទ្ធភាពយកឈ្នះនូវការផលិតឡើងវិញតាមលក្ខណៈរូបសាស្ត្រធម្មជាតិឬជាឧបសគ្គដល់ការផ្តុំបញ្ចូលគ្នាឡើងវិញ ហើយក៏មិនមែនជាបច្ចេកទេសប្រើប្រាស់នៅក្នុងការបង្កាត់ពូជ ឬ ការជ្រើសរើសតាមរបៀបបុរាណ ។

**អាស៊ីតឌីអុកស៊ីរីបូនុយក្លេអ៊ិក** (DNA) ៖ ជាពាក្យកាត់សម្រាប់ deoxyribonucleic acid ដែលពីមុនគេហៅថា desoxyribonucleic acid ។ ជាច្រវ៉ាក់ប៉ូលីម៊ែរវែងមួយនៃដេអុកស៊ីរីបូនុយក្លេអូទីត ។

ROYAUME DU CAMBODGE
MINISTRE DU PALAIS ROYAL

DNA ជាបង្គរបស់រូបធាតុហ្សែននៃសារពាង្គកាយនិងធាតុកោសិកានានា ហើយជាទូទៅវាស្ថិតក្នុងទម្រង់ហេឡិចទ្វេ ។ ទោះបីជាយ៉ាងណាក្តី ចង្កោមហ្សែនរបស់វីរុសខ្លះកើតឡើងពីខ្សែDNA មួយចំណែក ឯខ្លះទៀតមានខ្សែRNA (Ribonucleic acid) មួយ ឬ ពីរ ។

**សារពាង្គកាយរស់** (Living Organisms)៖ សំដៅដល់អង្គជីវៈចម្រុះទាំងឡាយណាដែលមានសមត្ថភាពក្នុងការផ្ទេរ ឬ ផលិតឡើងវិញនូវសារធាតុសេនេទិច រួមទាំងសារពាង្គកាយដែលមិនអាចបន្តពូជបានវីរុស និងវីរ៉ូអ៊ីត ។

**អជីវិត** (Abiotic) ៖ អវត្តមានភាវៈរស់ ឬ សុចខុមព្រាណ ឬ សារពាង្គកាយមានជីវិត ។ ផ្នែកនៃសារពាង្គកាយរស់ដែលពុំមានលទ្ធភាពយកមកបន្តពូជ ដាំ ឬ ចិញ្ចឹមចាត់ទុកថាជាសមាសភាគអជីវិត ។

**ហានិភ័យ** (Risks) ៖ សំដៅលើគ្រោះថ្នាក់ដែលបណ្តាលមកពីសារពាង្គកាយកែច្នៃរស់មកលើបរិស្ថាន ជីវៈចម្រុះ សង្គម វប្បធម៌ និង សេដ្ឋកិច្ច ។

**ចលនាឆ្លងដែន** (Transboundary movement)៖ សំដៅលើចលនានៃសារពាង្គកាយកែច្នៃរស់ពីតំបន់មួយទៅតំបន់មួយទៀត ឬ ពីប្រទេសមួយទៅប្រទេសមួយទៀតតាមរយៈសកម្មភាពមនុស្ស ឬ ធម្មជាតិ ។

**ស្ថាប័នចំណោលជាតិ** (National Focal Point) ៖ សំដៅលើក្រសួងរបស់រដ្ឋាភិបាលដែលទទួលខុសត្រូវលើការងាររដ្ឋបាលដើម្បីទំនាក់ទំនងជាមួយលេខាធិការដ្ឋានអនុសញ្ញាជីវៈចម្រុះ និងពិធីសារកាតាហេះណាស្តីពីជីវសុវត្ថិភាពនិងភាគីនានាដែលជាសមាជិកពិធីសារ ។

**អជ្ញាធរសមត្ថកិច្ចជាតិ** (National Competent Authority) ៖ សំដៅលើក្រសួង ឬ នាយកដ្ឋានជំនាញដែលតែងតាំងដោយរាជរដ្ឋាភិបាលក្នុងការស្រាវជ្រាវ អភិវឌ្ឍន៍ ប្រើប្រាស់សារពាង្គកាយកែច្នៃរស់ និងវាយតម្លៃហានិភ័យបណ្តាលមកពីសារពាង្គកាយកែច្នៃរស់ ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

21/22

**ជីវៈចម្រុះ** (Biological Diversity) ៖សំដៅដល់បណ្តាលសារពាង្គកាយខុសគ្នានៅក្នុងប្រភេទតែមួយ ឬ ប្រភេទផ្សេងគ្នា និងបណ្តាសារពាង្គកាយរស់នៃគ្រប់លំដាប់ថ្នាក់ និងប្រភពទាំងអស់ រួមទាំងប្រព័ន្ធអេកូឡូស៊ីដែនដីគោក ដែនដីសមុទ្រ ដែនទឹកសាប និងបណ្តាទំនាក់ទំនងអេកូ-ឡូស៊ីដែលនៅក្នុងនោះមានប្រព័ន្ធអេកូឡូស៊ីទាំងនេះ ។

AUME DU CAMBODGE
RE DU PALAIS ROYAL